# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ២០ អនក្រ.បក
### ស្តីពីការបង្កើតស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា
### ប្រចាំសហភាពមីយ៉ាន់ម៉ា

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**មាត្រា ១ ._** បង្កើតស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសហភាពមីយ៉ាន់ម៉ា ដោយមាននិវេសនដ្ឋាននៅទីក្រុងយ៉ាងហ្គូន ។

**មាត្រា ២ ._** ស្ថានឯកអគ្គរាជទូតនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មទូតម្នាក់ ដែលមានឋានៈជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព ។

**មាត្រា ៣ ._** សមាសភាពមន្ត្រីការទូតផ្សេងទៀត យ៉ាងច្រើនបំផុតបួននាក់ នឹងត្រូវកំណត់តាមលក្ខការណ៍ការទូតនៃព្រះរាជាណាចក្រកម្ពុជា ។ រីឯបុគ្គលិកមិនមែនការទូតទាំងឡាយ នឹងត្រូវកំណត់ដោយរដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ៤ ._** មន្ត្រីការទូតតំណាងសេដ្ឋកិច្ច ពាណិជ្ជកម្ម ត្រូវជ្រើសតាំងយកអ្នកមានជំនាញពីមួយនាក់ទៅពីរនាក់។

**មាត្រា ៥ ._** អនុព័ន្ធយោធាមួយនាក់ ត្រូវជ្រើសតាំងដោយក្រសួងការពារជាតិ ។

មាត្រា ៦ ._ ប្រព័ន្ធហិរញ្ញកិច្ចសំរាប់មន្ត្រី និងបុគ្គលិក នៃស្ថានឯកអគ្គរាជទូត នឹងស្ថិតក្នុងប្រភេទ " ខ " ។

មាត្រា ៧ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការ អន្តរជាតិ សបរដ្ឋ ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី១៧ ខែមិនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ២១ អនក្រ.បក

## ស្តីពីការបង្កើតស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា

## ប្រចាំ ព្រះរាជាណាចក្រប្រ៊ុយណេដារូស្សាឡាម

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែល ប្រកាសឲ្យ ប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

មាត្រា ១ ._ បង្កើតស្ថានអគ្គរាជទូតកម្ពុជា ប្រចាំព្រះរាជាណាចក្រប្រ៊ុយណេដារូស្សាឡាម ដោយមាននិវេសនដ្ឋាននៅទីក្រុងបាន់ដា សេរី បេក្វាវ៉ាន ។

មាត្រា ២ ._ ស្ថានឯកអគ្គរាជទូតនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មទូតម្នាក់ ដែលមានឋានៈជាឯកអគ្គរាជទូត វិសាមញ្ញនិងពេញសមត្ថភាព ។

មាត្រា ៣ ._ សមាសភាពមន្ត្រីការទូតផ្សេងទៀត យ៉ាងច្រើនបំផុតបួននាក់ នឹងត្រូវកំណត់តាមលក្ខការណ៍ការទូត នៃព្រះរាជាណាចក្រកម្ពុជា ។ រីឯបុគ្គលិកមិនមែនការទូតទាំងឡាយ នឹងត្រូវកំណត់ដោយរដ្ឋមន្ត្រី ការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។